ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ : ០២៣/០១/២០១០ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១០

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រទាំង ១៤រូប**

**កម្មវត្ថុ :** អំពីសំណើសុំបកស្រាយមាត្រា ១៦ វក្យខណ្ឌទី៥ នៃច្បាប់ភូមិបាល

**យោង :** លិខិតលេខ ០០១/១០ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១០ របស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រទាំង ១៤រូប

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវ តំណាងរាស្ត្រ មេត្តាជ្រាបថា ចំពោះការស្នើសុំបកស្រាយមាត្រា ១៦ វក្យខណ្ឌទី៥ នៃច្បាប់ភូមិបាល តាមលិខិតលេខ ០០១/១០ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១០ ក្រុមប្រឹក្សាធម្មនុញ្ញសង្កេតឃើញថា ឯកឧត្តម លោកជំទាវ បានគូសបញ្ជាក់ច្បាស់ណាស់ថា សុំធ្វើការបកស្រាយវាក្យខណ្ឌទី៥ មាត្រា ១៦ នៃច្បាប់ភូមិបាលនោះ បានធ្វើឱ្យក្រុមប្រឹក្សាធម្មនុញ្ញមានការងឿងឆ្ងល់យ៉ាងខ្លាំង ពីព្រោះថា មាត្រា ១៦ នៃច្បាប់ភូមិបាលមានតែ ៤ វាក្យខណ្ឌប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចទទួលយកការស្នើសុំបកស្រាយដូចមានចែងក្នុងកម្មវត្ថុខាងលើរបស់ឯកឧត្តម លោកជំទាវ មកពិនិត្យបានឡើយ ។

សូមឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**
**ប្រធាន**
**ឯក សំអុល**